

# ការជម្រះក្តីកំបាំងមុខ ឆ្នាំ២០១២: បច្ចុប្បន្នភាពស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅ កម្ពុជា

របាយការណ៍សង្ខេប លីកាដូ
ខែមេសា ឆ្នាំ២០១២

លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# ការជម្រះក្តីកំបាំងមុខ ឆ្នាំ២០១២: បច្ចុប្បន្នភាពស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងឧបត្ត ក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា

---

របាយការណ៍សង្ខេប លីកាដូ

ខែមេសា ឆ្នាំ២០១២

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ:

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានា ថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

- **សេវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជនអំពីសិទ្ធិស្រ្តី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងគោរពច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/ ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org

# មាតិកា


សេចក្តីផ្តើម ........................................................................................................ ១

១. ទិដ្ឋភាពច្បាប់ជាតិ និងច្បាប់អន្តរជាតិ.......................................................................៣

២. ការដឹកជញ្ជូនជនជាប់ឃុំនៅកម្ពុជា-កាលពីពេលមុន និងបច្ចុប្បន្ន ......... ៥

ភាពអសកម្ម និងការចាប់ផ្តើមដែលមានកំហុសក្នុងរយៈពេល ២ ឆ្នាំ ...................... ៨

ការធ្វើប្រក្រតីកម្មនៃសវនាការកំបាំងមុខជនត្រូវចោទ ........................................ ១១

៣. ជនជាប់ឃុំប្រឈមនឹងគ្រោះថ្នាក់.......................................................................... ១៣

ទិន្នន័យសម្រាប់បណ្តាពន្ធនាគារនៅជាយរាជធានីភ្នំពេញ ................................. ១៥

៤. អនុសាសន៍ទាំងឡាយ.......................................................................................... ១៧

# សេចក្តីផ្តើម

នៅឆ្នាំ២០១០ អង្គការលីកាដូ បានរាយការណ៍អំពីការជម្រះក្តីកំបាំងមុខទៅលើបណ្តឹងឧទ្ធរណ៍យ៉ាងច្រើន ក្នុងករណីព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា[១]។ ពិរុទ្ធជនរាប់រយនាក់ត្រូវបានជាប់ឃុំនៅក្នុងពន្ធនាគារខេត្ត អ្នកទាំងនោះ មិនអាចមកចូលរួមសវនាការនៅរាជធានីភ្នំពេញបានឡើយ ដោយសារគ្មានថវិកាចំណាយលើការដឹកជញ្ជូន ការរៀបចំមិនបានល្អរវាងពន្ធនាគារ និងតុលាការ ជាងនេះទៅទៀត គឺដោយមូលហេតុគ្មានការយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់អ្នកទាំងនោះ។ អស់រយៈពេល ២ ឆ្នាំកន្លងមកហើយ ដែលបញ្ហានេះ នៅតែមិនទាន់បានលើកយកមកធ្វើការដោះស្រាយ។

គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១២នេះ តាមការសិក្សាស្រាវជ្រាវរបស់អង្គការលីកាដូ មានពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ប្រមាណជិត ៨០០ នាក់ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារចំនួន ១១ខេត្ត។ ដូចករណីក្នុងឆ្នាំ២០១០ អគ្គនាយកដ្ឋានពន្ធនាគារនៅតែពុំទាន់មានមធ្យោបាយ



*សាលាឧទ្ធរណ៍រាជធានីភ្នំពេញ*

[១] សូមមើល "សវនាការកំបាំងមុខ: សិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា" របាយការណ៍លីកាដូ ខែមីនា ឆ្នាំ២០១០។

ដឹកជញ្ជូនពិរុទ្ធជនទាំងនេះ ដើម្បីទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅរាជធានីភ្នំពេញ។ ប្រព័ន្ធគ្រប់គ្រងពន្ធនាគារខ្វះរថយន្តដឹកជញ្ជូន សាំង បុគ្គលិក និងថវិកាចាំបាច់សម្រាប់បណ្តាញដឹកជញ្ជូនពិរុទ្ធជន ដែលនៅឆ្ងាយដាច់ស្រយាល។

សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ គឺជាសិទ្ធិមូលដ្ឋានក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌[២]។ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការបំពេញសិទ្ធិនេះ តម្រូវឲ្យមានវត្តមានជនត្រូវចោទក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍។ ផ្ទុយទៅវិញសិទ្ធិនេះ ត្រូវបានគេរំលោភបំពានជាប្រចាំ។ ដំណោះស្រាយតែមួយគត់សម្រាប់ពិរុទ្ធជនភាគច្រើនបំផុត ដែលចង់ចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន គឺត្រូវចំណាយប្រាក់សំរាប់ដឹកជញ្ជូន ដោយខ្លួន ឯង ដែលជាទម្លាប់អនុវត្តមួយមានន័យស្មើនឹងដាក់ស្លាកកំណត់តម្លៃទៅលើសិទ្ធិជាមូល ដ្ឋានទាំងនេះរបស់ប្រជាពលរដ្ឋកម្ពុជា។

[២] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ["ICCPR"] មាត្រា ១៤ (៥) (ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជាតាមរយៈរដ្ឋធម្មនុញ្ញត្រង់មាត្រា ៣១)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ["CCP"] មាត្រា៣៧៥។

## ១. ទិដ្ឋភាពច្បាប់ជាតិ និងច្បាប់អន្តរជាតិ

សារៈសំខាន់នៃការចូលរួមរបស់ជនត្រូវចោទ ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងព្រហ្មទណ្ឌ ត្រូវបានលើកមកបង្ហាញដោយពិស្តារ ក្នុងរបាយការណ៍របស់អង្គការលីកាដូ ។ កន្លងមករបាយការណ៍នោះ ក៏បានលើកយកករណីនេះ មកបង្ហាញម្តងហើយម្តងទៀត។

ច្បាប់កម្ពុជាតម្រូវថា ជនជាប់ឃុំដែលជាប់បណ្តឹងឧទ្ធរណ៍ "ត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាឲ្យទៅនៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍"។[៣] តាមទ្រឹស្តីការផ្ទេរនេះគួរតែកើតឡើង បន្ទាប់ពីតុលាការជូនដំណឹងដល់អគ្គព្រះរាជអាជ្ញា អំពីកាលបរិច្ឆេទសវនាការ។[៤] តាមពិត ការអនុវត្តន៍បែបនេះ កម្រកើតមានណាស់។

វត្តមានរបស់ជនត្រូវចោទមានសារៈសំខាន់ ក្នុងការធានាសវនាការប្រកបដោយយុត្តិធម៌លើបណ្តឹងឧទ្ធរណ៍នៅកម្ពុជា ដោយសារចរិតលក្ខណៈនីតិវិធីឧទ្ធរណ៍របស់ប្រទេសនេះ។ ក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យចៅក្រមសួរចម្លើយជនជាប់ចោទនៅពេលសវនាការលើបណ្តឹងឧទ្ធរណ៍ និងអាចអនុញ្ញាតឲ្យលើកជាសំណួរចោទសួរជនជាប់ចោទស្តាប់ចម្លើយចុងចោទ ពិនិត្យអង្គហេតុឡើងវិញ និងបើកសវនាការឡើងវិញលើអង្គសេចក្តី[៥] ប្រសិនបើតុលាការរកឃើញថា សាលក្រមដើមគ្មានសុពលភាព។ នីតិវិធីនេះ មិនអាចអនុវត្តទៅបានទេ នៅពេលណាគ្មានវត្តមានជនជាប់ចោទក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងព្រហ្មទណ្ឌ។

ប្រសិនបើជនត្រូវចោទគ្មានវត្តមានក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ទេ នោះសេចក្តីសម្រេចរបស់តុលាការត្រូវបានចាត់ថ្នាក់ជា "សាលដីកាកំបាំងមុខ"។[៦] តាមទ្រឹស្តីជនជាប់ចោទ បន្ទាប់មកមានសិទ្ធិប្តឹងជំទាស់ ដើម្បីមោឃភាពសាលដីកាកំបាំងមុខ[៧] ថ្វីបើតាមការ

---

[៣] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣៨៩

[៤] មាត្រា៣៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[៥] មាត្រា៣៩៣ - ៣៩៥ និងមាត្រា៤០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[៦] មាត្រា៣៦២ និងមាត្រា៤០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[៧] មាត្រា៤០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

អនុវត្តជាក់ស្តែង ការប្តឹងបែបនេះ មិនសូវកើតមានឡើងក៏ដោយ។ ការប្តឹងជំទាស់នេះ នាំឲ្យបើកសវនាការសារជាថ្មី ដែលជនជាប់ចោទត្រូវតែមានវត្តមានក្នុងសវនាការនោះ ជាចាំបាច់។[៨]

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២[៩] ចែងថា " ជនគ្រប់រូប ដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យឡើងវិញស្របតាមច្បាប់ ទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសទៅលើខ្លួន"។ កតិកាសញ្ញានេះ ក៏តម្រូវផងដែរឲ្យមានវត្តមានជនជាប់ចោទ "ក្នុងការសម្រេចចោទប្រកាន់ពីបទព្រហ្មទណ្ឌ[១០]ណាមួយប្រឆាំងទៅលើខ្លួន"។

ទន្ទឹមនឹងយុត្តាធិការឧទ្ធរណ៍នៅកម្ពុជា តម្រូវឲ្យមានការចូលរួមពីជនជាប់ចោទក៏ដោយក៏បទបញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយពិតជាតម្រូវថាជនជាប់ចោទត្រូវតែមានវត្តមានយ៉ាងពិតប្រាកដផងដែរ។

---

[៨] មាត្រា៤១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[៩] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា តាមរយៈរដ្ឋធម្មនុញ្ញត្រង់មាត្រា៣១។

[១០] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា១៤(៣)(ឃ)។

# ២. ការដឹកជញ្ជូនជនជាប់ឃុំនៅកម្ពុជា-កាលពីពេលមុន និងបច្ចុប្បន្ន

នៅឆ្នាំ២០១០ អង្គការលីកាដូ បានរាយការណ៍ថា ពិរុទ្ធជនកម្ពុជា ដែលឃុំខ្លួន នៅតាមបណ្ដាខេត្តកម្រនឹងផ្ទេរ "ឲ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលនៅជិតជាងគេបំផុត នៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍" ដូចដែលតម្រូវតាមក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។ ស្ថានភាពនេះ មិនខុសគ្នានឹងស្ថានភាពដូចនៅឆ្នាំ២០១២ នេះឡើយ។



*រថយន្តដឹកអ្នកទោសរបស់ពន្ធនាគារខេត្តកំពង់ឆ្នាំង*

បណ្ដាញដឹកជញ្ជូនជនជាប់ឃុំ ដែលនៅឆ្ងាយដាច់ស្រយាលរបស់អគ្គនាយកដ្ឋានពន្ធនាគារ នៅតែជាស្រមោលនៃអ្វីដែលត្រូវការបំពេញតាមលក្ខខណ្ឌតម្រូវនានារបស់ច្បាប់។ ជនជាប់ឃុំជារឿយៗ ត្រូវបានគេផ្ទេរចេញដើម្បីកាត់បន្ថយភាពចង្អៀតណែន ប៉ុន្តែការដឹកជញ្ជូនពួកគេទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍មិនដែលឮគេថា ធ្វើឡើងដោយការឧបត្ថម្ភសោហ៊ុយជាសាធារណៈ និងឥតបង់ថ្លៃឡើយ។

ប្រធានពន្ធនាគារមួយចំនួនដែល ត្រូវបានធ្វើសម្ភាសន៍ដោយចាប់តាំងពីមានរបាយការណ៍អង្គការលីកាដូ កាលពីឆ្នាំ២០១០ បានថ្លែងឲ្យដឹងថា ពួកគេនៅតែបន្តខ្វះខាតលទ្ធភាពក្នុងការដឹកជញ្ជូនជនជាប់ឃុំទៅចូលរួមសវនាការសាលាឧទ្ធរណ៍។ ប្រធានពន្ធនាគារខ្លះមានរថយន្ត ប៉ុន្តែគ្មាននណាម្នាក់មានលុយទិញប្រេងសាំង ឬ ខ្វះបុគ្គលិកធ្វើការលើសម៉ោង និងចំណាយផ្សេងៗ។ ប្រធានពន្ធនាគារខ្លះទៀត បានសម្ដែងសេចក្ដីព្រួយបារម្ភផងដែរ ចំពោះការខ្វះខាតចំនួនបុគ្គលិក ដែលត្រូវធ្វើដំណើរអមជនជាប់ឃុំ។[១១]

[១១] នេះជាការព្រួយបារម្ភមួយ ដោយសារតែការធ្វើដំណើរទៅកាន់ភ្នំពេញត្រូវប្រើបុគ្គលិកច្រើននាក់ពេញ ១ ថ្ងៃ ឬ ច្រើនថ្ងៃ។ ប្រធានពន្ធនាគារភាគច្រើនបានប្រាប់អង្គការលីកាដូ ថា ពួកគេមិនមានបុគ្គលិកគ្រប់គ្រាន់ដើម្បីគ្រប់គ្រងសភាពការនេះ សូម្បីតែស្ថិតក្នុងកាលៈទេសៈពិសេសក៏ដោយ let alone on a regular basis។

ប្រធានពន្ធនាគារខេត្តមួយរូបបានថ្លែងថា គាត់នឹងចំណាយទៅលើការដឹកជញ្ជូន ប្រសិនបើសាលាឧទ្ធរណ៍ចេញដីកាបង្គាប់ថា វា "ចាំបាច់" ត្រូវតែឲ្យជនជាប់ឃុំទៅចូលរួមសវនាការ ប៉ុន្តែគាត់ថ្លែងបន្ថែមថា ករណីបែបនេះ កើតមានតែម្តងទេក្នុងមួយឆ្នាំ។ ប្រធានពន្ធនាគារខេត្តពោធិ៍សាត់បង្ហើបឲ្យដឹងនូវបញ្ហានេះ តាមអត្ថបទកាសែត The Cambodia Daily ចុះផ្សាយនៅខែធ្នូ ឆ្នាំ២០១១ ដោយនិយាយថា ជនជាប់ឃុំជួនកាលមិនត្រូវបានផ្ទេរទៅកាន់រាជធានីភ្នំពេញទេ ដោយសារតែមាន "លិខិតបង្គាប់ឲ្យដោះលែងជនជាប់ឃុំ...ដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ឃុំទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ បានមកដល់ពន្ធនាគារហួសកាលបរិច្ឆេទសវនាការទៅហើយ។[១២]

របាយការណ៍សកម្មភាពប្រចាំឆ្នាំ២០០៩ របស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលបានបោះពុម្ពផ្សាយក្នុងខែមិថុនា ឆ្នាំ២០១០ បានធ្វើការកត់សម្គាល់ត្រង់ៗថា "ការធ្វើដំណើរអមដើម្បីការពារសន្តិសុខជនជាប់ឃុំទៅកាន់សាលាឧទ្ធរណ៍ ត្រូវបានខកខានជាច្រើនដង ដោយសារគ្មានមធ្យោបាយដឹកជញ្ជូន[១៣]គ្រប់គ្រាន់"។ របាយការណ៍ឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានពន្ធនាគារនេះ បានធ្វើសេចក្តីសង្កេតស្រដៀងគ្នាដោយលើកឡើងអំពី "ការខ្វះថវិកាសម្រាប់អនុរក្សពន្ធនាគារ ធ្វើដំណើរអមការពារសន្តិសុខជនជាប់ឃុំ និងមធ្យោបាយដឹកជញ្ជូនពួកគេទៅកាន់រាជធានីភ្នំពេញ"។[១៤] របាយការណ៍បានអះអាងថា មានជនជាប់ឃុំសរុប៣២៦នាក់ ត្រូវបានគេដឹកជញ្ជូនទៅចូលរួមសវនាការ លើបណ្តឹងឧទ្ធរណ៍នៅឆ្នាំ២០១០ ប៉ុន្តែមិនបានបញ្ជាក់ថាមានជនជាប់ឃុំចំនួនប៉ុន្មាននាក់ ដែលបានមកពីតាមបណ្តាខេត្ត។[១៥] របាយការណ៍ប្រចាំឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលបានបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ មិនបាននិយាយអំពីការផ្ទេរជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍ក្រោមចំណងជើងស្តីពី "ការផ្ទេរ និងមធ្យោបាយដឹកជញ្ជូន"[១៦] ឡើយ។ ទោះបីយ៉ាងណាក៏ដោយពិតជាកត់សម្គាល់ឃើញថា ការផ្ទេរជនជាប់ឃុំយ៉ាងច្រើនសន្ធឹកសន្ធាប់ គឺត្រូវធ្វើឡើងដើម្បីសម្រួលដល់ភាពចង្អៀតណែន។

---

[១២] Kuch Naren: "ជនជាប់ឃុំភាគច្រើនគ្មានវត្តមានក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍" កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១១។

[១៣] អគ្គនាយកដ្ឋានពន្ធនាគារ: "របាយការណ៍ប្រចាំឆ្នាំ២០០៩ និងសេចក្តីណែនាំឆ្នាំ២០១០" ដែលបានបោះពុម្ពផ្សាយនៅខែមិថុនា ឆ្នាំ២០១០ ត្រង់ទំព័រ៣ (ការបកប្រែជាភាសាអង់គ្លេសផ្លូវការ)។

[១៤] អគ្គនាយកដ្ឋានពន្ធនាគារ: "សមិទ្ធផលនៅឆ្នាំ២០១០ និងការធ្វើផែនការណ៍សម្រាប់ឆ្នាំ២០១១" ដែលបោះពុម្ពផ្សាយនៅខែមករា ឆ្នាំ២០១១ ត្រង់ទំព័រ៣ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ) ["របាយការណ៍ប្រចាំឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានពន្ធនាគារ]។

[១៥] យោងឯកសារដូចគ្នានឹងជើងទំព័រ១៤ នេះប្រៀបធៀបទៅនឹងការធ្វើដំណើរដែលមាន ៩,៣១៤ ជើងទៅកាន់សាលាដំបូងនានា។

[១៦] អគ្គនាយកដ្ឋានពន្ធនាគារ: "សមិទ្ធផលនៅឆ្នាំ២០១១ និងគោលដៅសម្រាប់ឆ្នាំ២០១២" ដែលបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រ៥ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។

ប្រធានពន្ធនាគារមួយចំនួន បានប្រាប់អង្គការលីកាដូថា ជម្រើសតែមួយគត់សម្រាប់ជនជាប់ឃុំ ដែលចង់ទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នោះ គឺពួកគេត្រូវចំណាយប្រាក់ "សម្រាប់ដឹកជញ្ជូនដោយខ្លួនឯង"។

ប្រធានពន្ធនាគារមួយរូបបានទទួលស្គាល់ហេតុការណ៍នេះ ដោយស្មៀមស្ងាត់តាមអត្ថបទកាសែត The Cambodia Daily ដែលចុះផ្សាយនៅខែធ្នូ ឆ្នាំ២០១១ ដោយទទួលស្គាល់ថា សមាជិកគ្រួសាររបស់ជនជាប់ឃុំ "ជូនកាល" ត្រូវចំណាយលុយកាក់សម្រាប់មធ្យោបាយធ្វើដំណើរ។[១៧] នៅក្នុងអត្ថបទកាសែតដ៏ដែលនេះ អ្នកសារព័ត៌មានឈ្មោះ Ros Sokhet ដែលត្រូវបានជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ ពីបទបរិហារកេរ្តិ៍បានថ្លែងថា គាត់តែងតែចំណាយលុយកាក់សម្រាប់មធ្យោបាយធ្វើដំណើរ ទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់គាត់ ថ្វីត្បិតតែគាត់ត្រូវបានឃុំខ្លួននៅជាយរាជធានីភ្នំពេញ[១៨] ក៏ដោយ។

គាត់ពោលថា "គួរឲ្យអស់សំណើច យើងត្រូវចំណាយលុយកាក់ទៅលើសាំងប្រេង និងម្ហូបអាហារសម្រាប់មន្ត្រីពន្ធនាគារ ដើម្បីដឹកជញ្ជូនពួកយើង [ទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍]"។ គាត់ពោលបន្ថែមទៀតថា តម្លៃលើមធ្យោបាយធ្វើដំណើរបែបនេះ មានកំណត់ចាប់ពី ១ ម៉ឺនទៅ ២ ម៉ឺនរៀល (២.៥ ទៅ ៥ ដុល្លារ)។[១៩]

តាមការសិក្សាស្រាវជ្រាវរបស់អង្គការលីកាដូ បង្ហាញឲ្យឃើញថា ជនជាប់ឃុំម្នាក់ៗនៅតាមបណ្តាខេត្ត ដែលចង់ឲ្យគេដឹកទៅកាន់សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញនឹងត្រូវបង់លុយប្រហែល ១០០ ដុល្លារទៅឲ្យមន្ត្រីពន្ធនាគារ ដោយមិនបាច់ស្នាក់នៅសូម្បីតែ ១ យប់។[២០]

[១៧] Kuch Naren: "ជនជាប់ឃុំភាគច្រើនបំផុតគ្មានវត្តមានក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍" កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១១។

[១៨] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៧។

[១៩] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៨។

[២០] តាមការគណនាត្រួសៗបញ្ជាក់ច្បាស់ថា គ្រាន់តែតម្លៃសាំងលើស ១០០ ដុល្លារសម្រាប់ជនជាប់ឃុំធ្វើដំណើរពីពន្ធនាគាខេត្តដាច់ស្រយាលមកកាន់រាជធានីភ្នំពេញ។ ឧ: ពីខេត្តសៀមរាបទៅភ្នំពេញមានចម្ងាយ ៦២០ គម ទាំងទៅទាំងមក។ អាចប្រើសាំងប្រហាក់ប្រហែល ១២ លីត្រ សម្រាប់ចម្ងាយផ្លូវ ១០០ គម - ទំនងជាអត្រាសមស្របសម្រាប់រថយន្តដឹកជញ្ជូន - អគ្គនាយកដ្ឋានពន្ធនាគារត្រូវការសាំងប្រហែល ៧៥ លីត្រសម្រាប់ធ្វើដំណើរ។ ក្នុង ១ លីត្រថ្លៃ ១.៩០ ដុល្លារ តម្លៃសាំងអាចថ្លៃដល់ទៅ ១០៥ ដុល្លារ។

## ភាពអសកម្ម និងការចាប់ផ្ដើមដែលមានកំហុសក្នុងរយៈពេល ២ ឆ្នាំ

ប្រការដែលគ្មានវិធានការជាក់លាក់ គឺគួរឲ្យខកចិត្ត ដោយសារមន្ត្រីអគ្គនាយកដ្ឋានពន្ធនាគារបានសន្យាថា នឹងលើកយកស្ថានភាពនេះ មកដោះស្រាយជាច្រើនលើកកន្លងមកហើយ។

នៅខែឧសភា ឆ្នាំ២០១០ ភ្លាមៗបន្ទាប់ពីចេញផ្សាយរបាយការណ៍ឆ្នាំ២០១០ របស់អង្គការលីកាដូ ឯកឧត្ដម ហេង ហាក់ អតីតអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារបានប្រាប់កាសែត Phnom Penh Post ថាមានការទទួលស្គាល់ "ការកង្វះសេវាទាំងឡាយ" សម្រាប់មធ្យោបាយដឹកជញ្ជូន[២១]ជនជាប់ឃុំ។ ប៉ុន្តែលោកថ្លែងថា អាជ្ញាធរ "មិនបានព្រងើយកន្តើយនឹងបញ្ហានេះទេ ឥឡូវនេះយើងកំពុងពិភាក្សាគ្នាជាមួយសាលាឧទ្ធរណ៍ និងអង្គការសហប្រជាជាតិ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហានេះ"។

លោកមានប្រសាសន៍បន្តដោយកត់សម្គាល់ថា ប្រទេសផ្សេងៗទៀតបានលើកបញ្ហានានាស្រដៀងគ្នានេះ មកធ្វើការដោះស្រាយតាមរយៈការប្រើប្រាស់សវនាការពីចម្ងាយភ្ជាប់ប្រព័ន្ធវីឌីអូរវាងតុលាការ និងពន្ធនាគារទាំងឡាយ ដែលអនុញ្ញាតឲ្យជនជាប់ឃុំចូលរួមសវនាការ ដោយមិនបាច់មានវត្តមាន[២២]ជាក់ស្ដែងរបស់អ្នកទាំងនោះនៅក្នុងសវនាការ។

របាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានពន្ធនាគារបានកត់សម្គាល់ថា អគ្គនាយកដ្ឋានពន្ធនាគារកំពុងតែសហការគ្នាជាមួយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាដើម្បី "ធ្វើការសិក្សាស្រាវជ្រាវទៅលើករណីពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍ទូទាំងប្រទេស ក្នុងគោលបំណងសហការជាមួយព្រះរាជអាជ្ញា" ដើម្បីស្វែងរកដំណោះស្រាយ។[២៣] របាយការណ៍បានប្រាប់ឲ្យដឹងថាអគ្គនាយកដ្ឋានពន្ធនាគារបានរៀបចំសិក្ខាសាលាចំនួន ២ ថ្ងៃផងដែរ ដោយផ្ដល់ការណែនាំដល់បុគ្គលិកពន្ធនាគារ ដើម្បីចងក្រងទិន្នន័យឲ្យបានត្រឹមត្រូវទាក់ទងនឹងពិរុទ្ធជន

---

[២១] James O'Toole and Chhay Channy: "មានជនជាប់ឃុំរាប់រយនាក់ ត្រូវបានគេបដិសេធនូវសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍: របាយការណ៍អង្គការមិនមែនរដ្ឋាភិបាល" កាសែត Phnom Penh Post ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០។

[២២] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៩។

[២៣] របាយការណ៍ប្រចាំឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានពន្ធនាគារត្រង់ទំព័រ៥។

ជាប់បណ្តឹងឧទ្ធរណ៍។[២៤] នេះជាជំហានវិជ្ជមានមួយពីព្រោះប្រធានពន្ធនាគារខ្លះ បានទទួលស្គាល់ថា ជួនកាលគេក៏មិនបានដឹងថា មានជនជាប់ឃុំប៉ុន្មាននាក់ ដែលនៅជាប់បណ្តឹងឧទ្ធរណ៍។ ជាញឹកញាប់ជនជាប់ឃុំខ្លួនឯងក៏មិនអាចដឹងថា ខ្លួនជាប់បណ្តឹងឧទ្ធរណ៍ដែរ។ ការទទួលបានទិន្នន័យត្រឹមត្រូវ អាចនឹងកត់សម្គាល់នូវជំហានមួយយ៉ាងមានសារៈសំខាន់ និងសមរម្យបំផុតឆ្ពោះទៅរកការដោះស្រាយបញ្ហាបែបនេះ។

អ្នកស្រាវជ្រាវខាងពន្ធនាគារអង្គការលីកាដូ បានសាកសួរជនជាប់ឃុំ និងប្រធានពន្ធនាគារមួយចំនួនតូច អំពីការអនុវត្តន៍គម្រោងសិក្សាស្រាវជ្រាវលើបណ្តឹងឧទ្ធរណ៍ ហើយពួកគេបញ្ជាក់ថា គម្រោងនេះ ពិតជាកំពុងដំណើរការមែន ទោះបីជួបប្រទះនឹងវិបត្តិខ្លះៗក៏ដោយ។ ឧ: គោលដៅមួយរបស់គម្រោងនេះ គឺត្រូវស្វែងរកពហុប្រភពព័ត៌មានមន្ត្រីពន្ធនាគារ និងជនជាប់ឃុំខ្លួនឯង និងធ្វើការបញ្ជាក់ព្រមទាំងផ្ទៀងផ្ទាត់ព័ត៌មាននេះ។ ប៉ុន្តែអ្នកស្រាវជ្រាវខាងពន្ធនាគារអង្គការលីកាដូ បានរកឃើញថា ជាញឹកញាប់ជនជាប់ឃុំមិនត្រូវបានគេពិគ្រោះយោបល់ទេ នៅអំឡុងពេលដំណើរការ។ ហេតុដូច្នេះនៅទីបំផុតទិន្នន័យដែលប្រមូលបាន បានបន្ទោតាមទិន្នន័យ ដែលមានរួចមកហើយ នៅការិយាល័យចុះបញ្ជីសំណុំរឿងនៅតាមពន្ធនាគារ។ តាមដឹងមកវិធានការតាមដានបន្តកំពុងតែដំណើរការទៅមុខ។

មានសញ្ញាដែលគួរឲ្យសង្ឃឹមផ្សេងៗទៀត: នៅពាក់កណ្តាលឆ្នាំ២០១១ ប្រធានពន្ធនាគារមួយរូបបានប្រាប់អង្គការលីកាដូឲ្យបានដឹងថា សាលាឧទ្ធរណ៍កំពុងព្យាយាម "រៀបចំជាក្រុមៗ" នូវដំណើរការបណ្តឹងឧទ្ធរណ៍ ដើម្បីបើកសវនាការឲ្យបានច្រើនលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ឃុំជាបន្តបន្ទាប់។ ប្រការនេះ នឹងនាំមកនូវការសន្សំសំចៃចំនួនបុគ្គលិក និងថវិកាចំណាយលើប្រេងសាំង។ នៅពេលជាមួយគ្នានោះ អគ្គនាយកដ្ឋានពន្ធនាគារបានកត់សម្គាល់ឃើញថា អគ្គនាយកដ្ឋាននេះ បានធ្វើសំណើពិសេសមួយសុំប្រេងសាំងចំនួន ២,០០០ លីត្រ ជាពិសេសសម្រាប់ដឹកជញ្ជូនជនជាប់ឃុំទៅសាលាឧទ្ធរណ៍នៅឆ្នាំ២០១១[២៥] កន្លងទៅនេះ។ ហើយរបាយការណ៍បញ្ចប់ឆ្នាំ២០១១ បានបង្ហាញ

---

[២៤] យោងឯកសារដូចគ្នានឹងជើងទំព័រទី២១។

[២៥] អគ្គនាយកដ្ឋានពន្ធនាគារ: "របាយការណ៍ឆមាសទី១ ឆ្នាំ២០១១ និងសេចក្តីណែនាំសម្រាប់ឆមាសទី២ ឆ្នាំ២០១១" បោះពុម្ពផ្សាយនៅខែឧសភា ឆ្នាំ ២០១១ ត្រង់ទំព័រទី៦ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ) ["របាយការណ៍ប្រចាំឆ្នាំ២០១១ ឆមាសទី១ របស់អគ្គនាយកដ្ឋានពន្ធនាគារ"]។

ឲ្យដឹងផងដែរថា ទីភ្នាក់ងារនេះ បានស្នើសុំថវិកាទិញរថយន្ត[២៦] ចំនួន ២ គ្រឿង សម្រាប់ដឹកជញ្ជូនជនជាប់ឃុំ។

ជាអកុសលមិនមានការបញ្ជាក់ឲ្យបានច្បាស់ ថាតើការស្នើសុំរថយន្តដឹកជញ្ជូន និងប្រេងសាំង ត្រូវបានអនុម័តយល់ព្រម ឬ "ការរៀបចំជាក្រុមៗ" នូវដំណើរការបណ្តឹងឧទ្ធរណ៍នោះ ត្រូវបានគេអនុវត្ត ឬ យ៉ាងណានោះទេ។ ប្រសិនបើការស្នើសុំរថយន្តដឹកជញ្ជូន និងប្រេងសាំង និងការរៀបចំបណ្តឹងឧទ្ធរណ៍ជាក្រុមៗត្រូវបានអនុម័តទំនងជាមិនមានឥទ្ធិពល[២៧] ច្រើនទេ។ តាមការស្រាវជ្រាវពីអង្គការលីកាដូ បានរកឃើញថា ជនជាប់ឃុំនៅតែបន្តខកខានមិនបានទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជាលក្ខណៈប្រព័ន្ធដោយសារខ្វះមធ្យោបាយដឹកជញ្ជូន។

ជំហានជាវិជ្ជមានបំផុតចាប់តាំងពីឆ្នាំ២០១០ គឺប្រហែលជាការសាងសង់រួចរាល់ថ្មីៗនូវអគារថ្មីមួយនៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញ។ អគារថ្មីនេះ បង្កើនចំនួនបន្ទប់សវនាការពី ១ បន្ទប់រហូតដល់ ៣ បន្ទប់។ តាមទ្រឹស្តី ប្រការនេះអាចចាត់ការបណ្តឹងឧទ្ធរណ៍បានយ៉ាងឆាប់រហ័សជាងពេលមុនៗ ហើយអាចជួយសម្រួលដល់សំណើ "ក្នុងការរៀបចំជាក្រុមៗ" នូវបណ្តឹងឧទ្ធរណ៍សម្រាប់ជនជាប់ឃុំ ដែលត្រូវការដឹកជញ្ជូនមកកាន់រាជធានីភ្នំពេញ។

---

[២៦] អគ្គនាយកដ្ឋានពន្ធនាគារ: "សមិទ្ធិផលឆ្នាំ២០១១ និងគោលដៅសំរាប់ឆ្នាំ២០១២" ដែលបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រ១១ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។

[២៧] មិនមានការបញ្ជាក់ច្បាស់លាស់ផងដែរ ថាតើប្រេងសាំងចំនួន២,០០០ លីត្រសម្រាប់ឆ្នាំប្រតិទិន ១ ឆ្នាំ មានឥទ្ធិពល ឬ ត្រូវបានគេប្រើប្រាស់ចំគោលដៅពិតប្រាកដ ឬ យ៉ាងណានោះទេ។ តាមការប្រៀបធៀបប្រធានពន្ធនាគារមួយរូបបានប្រាប់អង្គការលីកាដូ នៅឆ្នាំ២០១០ ឲ្យបានដឹងថា រដ្ឋាភិបាលផ្តល់ប្រេងសាំងឲ្យគាត់ចំនួន ៨០០ លីត្រក្នុង ១ ខែ ដែលចំនួននេះ ស្ទើរតែមិនគ្រប់សម្រាប់ចាក់ម៉ាស៊ីនភ្លើង ដែលត្រូវប្រើរយៈពេល ៣ ម៉ោងក្នុង ១ ថ្ងៃ។ ម៉ាស៊ីនភ្លើង គឺជារបស់ដ៏ចាំបាច់ ដោយសារតែពន្ធនាគារមិនមានភ្ជាប់បណ្តាញផ្គត់ផ្គង់ភ្លើងអគ្គិសនី។

## ការធ្វើប្រក្រតកម្មនៃសវនាការកំបាំងមុខជនត្រូវចោទ

ដោយសារគ្មានប្រព័ន្ធដឹកជញ្ជូនជនជាប់ឃុំ ដំណើរការសវនាការលើបណ្ដឹងឧទ្ធរណ៍នៅកម្ពុជាត្រូវធ្វើឡើងជាប្រចាំ ដោយគ្មានវត្តមានរបស់ចុងចោទក្នុងករណីព្រហ្មទណ្ឌ ។ ការរំលោភបំពាន ទៅលើសិទ្ធិទទួលបានការជម្រះក្ដីជាមួយ នឹងការបើកសវនាការកំបាំងមុខទាំងនេះ បានក្លាយទៅជាលក្ខណៈ ស្ថាប័នរហូត "ទៅជាការធម្មតា" ទៅហើយ។ យោងតាមការសិក្សាឃ្លាំមើលការជម្រះក្ដី ដែលចេញផ្សាយនៅខែមិថុនា ឆ្នាំ២០១០ ជនជាប់ចោទទាំងឡាយមិនមានវត្តមានចូលរួមសវនាការ[២៨] លើបណ្ដឹងឧទ្ធរណ៍ចំនួន៦៩%។



*សាលាឧទ្ធរណ៍នៃប្រទេសកម្ពុជាមានតែមួយគត់ នៅរាជធានីភ្នំពេញ*

ការរំពឹងទុកដែលថា ជនជាប់ចោទត្រូវតែចេញថ្លៃធ្វើដំណើរផ្ទាល់ខ្លួនសម្រាប់ទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ ក៏បានក្លាយទៅជាប្រក្រតីកម្មទៅហើយដែរ។ ដូចអ្វីៗផ្សេងទៀតស្ទើរតែគ្រប់យ៉ាងនៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជម្រះក្ដី បានក្លាយជាទំនិញមួយដែលអាចធានាសុវត្ថិភាពទៅបានតាមរយៈការសូកប៉ាន់តែប៉ុណ្ណោះ។ ជាការពិតហើយ ជនជាប់ឃុំភាគច្រើនបំផុតមិនអាចមានលទ្ធភាពទិញទំនិញមានតម្លៃបែបនេះទេ ដូច្នេះសវនាការបន្តធ្វើដោយកំបាំងមុខជនជាប់ចោទ ហើយឱកាសរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ត្រូវបាត់បង់។

ភស្តុតាងដែលបង្ហាញឲ្យឃើញថា ជាធម្មតាបែបនេះ គេអាចមើលឃើញតាមរយៈអាកប្បកិរិយាជនជាប់ឃុំនៅក្នុងពន្ធនាគារ និងនៅក្នុងប្រព័ន្ធតុលាការ។ នៅខែធ្នូ ក្រឡាបញ្ជីនៅតុលាការកំពូលមួយរូប បាននិយាយមើលស្រាលប្រការគ្រោះថ្នាក់ ដែលបង្កឡើង

[២៨] មជ្ឈមណ្ឌលសម្រាប់ពិនិត្យឡើងវិញនូវច្បាប់ ការផ្សះផ្សារ និងយុត្តិធម៌ issue 01-A, ខែមីនា ឆ្នាំ២០១០ ទំព័រ៥។ រិតតែភ្ញាក់ផ្អើលជាងនេះទៅទៀតនោះ គឺជាហេតុការណ៍ដែលថា ការជម្រះក្ដីទាំងនោះ ត្រូវបានធ្វើឡើងដោយកំបាំងមុខ ហើយគ្មានវត្តមានមេធាវីការពារក្ដីចំនួន៧១%។ សូមមើលឯកសារដូចគ្នាត្រង់ទំព័រ៦ មានសវនាការលើសពី៩០% ត្រូវបានឃ្លាំមើលក្នុងការសិក្សាដែលធ្វើឡើងដោយកំបាំងមុខជនជាប់ចោទ - ទាំងការជម្រះក្ដី និងបណ្ដឹងឧទ្ធរណ៍ - ប្រើពេលមិនដល់៣០ នាទីផង។

ដោយការខកខានរបស់ជនជាប់ឃុំមិនបានទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ ដោយ ប្រាប់កាសែត The Cambodia Daily ឲ្យបានដឹងថា "ថ្វីបើបណ្ដឹងឧទ្ធរណ៍ភាគច្រើនបំផុត ត្រូវបានគេបើកសវនាការកំបាំងមុខជនជាប់ចោទក៏ដោយ ក៏ពួកគេនៅតែមានមេធាវីការពារក្ដី និងតំណាងឲ្យពួកគេផងដែរ"។[២៩] ប្រធានពន្ធនាគារមួយរូប ដែលបានផ្ដល់កិច្ចសម្ភាសន៍សម្រាប់អត្ថបទដូចគ្នានេះ បានប្រាប់កាសែត The Cambodia Daily ថា វត្តមានមេធាវីការពារក្ដីឲ្យជនជាប់ចោទ ធានាថាប្រព័ន្ធបែបនេះនៅតែជាប្រព័ន្ធត្រឹមត្រូវ។

ច្បាប់ មិនគាំទ្រគោលជំហរបែបនេះទេ។

ដូចបានកត់សម្គាល់ក្នុងផ្នែក១ ខាងលើក្រមនីតិវិធីព្រហ្មទណ្ឌកំណត់លក្ខខណ្ឌថា ជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍ "ត្រូវតែផ្ទេរ ដោយគ្មានការពន្យារពេលឲ្យទៅនៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍"។

ច្បាប់តម្រូវឲ្យចៅក្រមសួរចម្លើយជនជាប់ចោទ[៣០] អនុញ្ញាតឲ្យជនជាប់ចោទនិយាយក្នុងនាមខ្លួន[៣១] ហើយធ្វើចំណាត់ថ្នាក់សាលដីកា ដែលគ្មានជនជាប់ចោទចូលរួមជា "សាលដីកាកំបាំងមុខ"[៣២]មួយ។ នៅពេលដែលជនជាប់ចោទ ត្រូវបានរារាំងមិនឲ្យទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន លទ្ធផលសាលដីកាជាមូលដ្ឋានត្រូវទុកជាអសារឥតការ។

ជាអកុសលជនជាប់ឃុំ ដែលចង់ប្ដឹងតវ៉ាទៅនឹងសាលដីកាកំបាំងមុខ ជាថ្មីម្ដងទៀត គេនឹងត្រូវបានរារាំងដោយបញ្ហាមធ្យោបាយដឹកជញ្ជូនៈ ប្រសិនបើអ្នកទាំងអស់នោះ មិនអាចទៅចូលរួមសវនាការដំបូងលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនបានផង យើងអាចសង្ស័យថា អ្នកទាំងនោះ នឹងមិនអាចទៅចូលរួមសវនាការដែលចាំបាច់ បន្ទាប់ពីបានប្ដឹងទាស់ដើម្បីមោឃភាពសាលដីកាកំបាំងមុខ[៣៣]។

---

[២៩] Kuch Naren: "ជនជាប់ឃុំភាគច្រើនបំផុតគ្មានវត្តមានក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍" កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១១។

[៣០] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៩៣។

[៣១] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៩៥។

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៦២ និងមាត្រា៤០៨។

[៣៣] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៤១៥។

# ៣. ជនជាប់ឃុំប្រឈមនឹងគ្រោះថ្នាក់

វាមានការលំបាកក្នុងការស្វែងយល់ថា តើមានជនជាប់ឃុំប៉ុន្មាននាក់ ដែលត្រូវ បាន រារាំង - ឬស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ពីការរារាំង - មិនឲ្យធ្វើដំណើរទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ការធ្វើ និងការរក្សាទុកកំណត់ហេតុនៅតាមបណ្តាពន្ធនាគារអាចមានភាពទន់ខ្សោយ តុលាការតែងតែមិនផ្តល់ព័ត៌មានទៅឲ្យពន្ធនាគារអំពីការវិវត្តន៍នៃរឿងក្តី ហើយសូម្បីតែជនជាប់ឃុំខ្លួនឯងអាចមានការភ័ន្តច្រឡំ ថាតើពួកគេបានប្តឹងឧទ្ធរណ៍ក្នុងនាមខ្លួនរួចហើយ ឬក៏មិនទាន់បានប្តឹង។ គ្មានទិន្នន័យថ្នាក់ជាតិដែលមានព័ត៌មានស្តីពីបណ្តឹងឧទ្ធរណ៍អោយបានត្រឹមត្រូវ និងមានបច្ចុប្បន្នភាពឡើយ។

ទិន្នន័យដែលបោះពុម្ពផ្សាយថ្មីៗបំផុតរបស់អគ្គនាយកដ្ឋានពន្ធនាគារ បង្ហាញឲ្យដឹងថា មានជនជាប់ឃុំដែលជាប់បណ្តឹងឧទ្ធរណ៍ចំនួន ៩៩៣ នាក់នៅទូទាំងប្រទេសចាប់គិតមកដល់ត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១[៣៤]។ នៅខែឧសភា ឆ្នាំ២០១១ ជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍មានចំនួន៩៦១[៣៥] នាក់។ ប៉ុន្តែទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារនេះជាទូទៅមិនបានបង្ហាញថា តើមានដើមបណ្តឹងឧទ្ធរណ៍ប៉ុន្មាននាក់ ដែលជាប់ឃុំនៅតាមបណ្តាខេត្ត បើប្រៀបធៀបទៅនឹងចំនួនដើមបណ្តឹងឧទ្ធរណ៍ ដែលត្រូវជាប់ឃុំនៅរាជធានីភ្នំពេញ។ ប្រភពមួយផ្សេងទៀតធ្វើការក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ បង្ហាញឲ្យដឹងថាចំនួននេះលើសពី១,៥០០ នាក់។

សម្រាប់របាយការណ៍នេះ អង្គការលីកាដូ អាចប្រមូលបានទិន្នន័យបណ្តឹងឧទ្ធរណ៍ពី ពន្ធនាគារចំនួន១១ នៅក្រៅរាជធានីភ្នំពេញ។ ព័ត៌មាននេះ ត្រូវបានផ្តល់ឲ្យទាំងស្រុងពីមន្ត្រីពន្ធនាគារ ហើយក្នុងករណីខ្លះព័ត៌មានដែលទទួលបានមិនគ្រប់គ្រាន់ឡើយ។ ថ្វីបើមានកំហុសឆ្គងជាសក្តានុពលខ្លះៗក៏ដោយ ក៏ទិន្នន័យនេះពិតជាផ្តល់នូវការយល់ដឹងស៊ីជម្រៅទៅលើបញ្ហាមួយចំនួនធំ។ មិនមែនគ្រាន់តែមានជនជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះទេ

---

[៣៤] អគ្គនាយកដ្ឋានពន្ធនាគារ: "សមិទ្ធិផលឆ្នាំ២០១១ និងគោលដៅសំរាប់ឆ្នាំ២០១២" ដែលបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រ៤ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។

[៣៥] របាយការណ៍ឆមាសទី១ ឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានពន្ធនាគារ ត្រង់ទំព័រ២។

ដែលទទួលរងផលប៉ះពាល់ពីការខ្វះបណ្តាញមធ្យោបាយដឹកជញ្ជូន ប៉ុន្តែមានជនជាប់ឃុំរាប់រយនាក់ ដែលទទួលរងផលប៉ះពាល់បែបនេះ។

តារាងខាងក្រោមប្រៀបធៀបចំនួនជនជាប់ឃុំ ដែលជាប់បណ្តឹងឧទ្ធរណ៍ក្នុងខែមករា ឆ្នាំ២០១០ កាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយរបស់អង្គការលីកាដូ ដោយមានទិន្នន័យពីខែកុម្ភៈ ឆ្នាំ២០១២។ ជាសារៈសំខាន់ពន្ធនាគារទាំងអស់លើកលែងតែពន្ធនាគារមួយ គឺពន្ធនាគារខេត្តព្រះសីហនុ បច្ចុប្បន្ននេះផ្ទុកជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍ចំនួនច្រើនជាងគេ ថ្វីបើនៅតាមពន្ធនាគារខ្លះដើមបណ្តឹងឧទ្ធរណ៍ ដែលជាជនជាប់ឃុំមានចំនួនតិចជាងបើគិតជាភាគរយ។

| ពន្ធនាគារ | ពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ ខែមករា ឆ្នាំ២០១០ | ចំនួនទណ្ឌិតសរុប ខែមករា ឆ្នាំ២០១០ | ពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ ខែកុម្ភៈ ឆ្នាំ២០១២ | ចំនួនទណ្ឌិតសរុប ខែកុម្ភៈ ឆ្នាំ២០១២ |
|---|---|---|---|---|
| មណ្ឌលអប់រំកែប្រែទី៣ | ៣៥៥ | ១,៤០០(២៥.៤%)[៣៦] | ៣៥៦ | ១,៤៩០(២៣.៩%) |
| សៀមរាប | ១១០ | ១,០៣១(១០.៧%) | ១២៣ | ១,១២០(១០.៩%) |
| កំពង់ធំ | ៥ | ១២១ (៤.១%) | ៣០ | ២៨២(១០.៦%) |
| ព្រះសីហនុ | ២៣ | ១១៤(២០.២%) | ១៦ | ១៦០(១០%) |
| កោះកុង | ១១ | ១១៣(៩.៧%) | ២៨ | ២០១(១៣.៩%) |
| កំពង់ឆ្នាំង | ២១ | ១៦៣(១២.៩%) | ២២ | ១២០(១៨.៣%) |
| ពោធិ៍សាត់ | ១៥ | ១០៩(១៣.៨%) | ២៨ | ១០៧(២៦.២%) |
| **សរុប** | **៥៤០** | **៣,០៥១(១៧.៧%)** | **៦០២** | **៣,៤៨០(១៧.៣%)** |
| **ទិន្នន័យរបាយការណ៍ពន្ធនាគារបន្ថែមក្នុងឆ្នាំ២០១២** | | | | |
| កំពង់ស្ពឺ[៣៧] | | | ៧០ | ២៥២(២៧.៨%) |
| កំពត | | | ៣៤ | ៣២៤(១០៥.៥%) |
| បាត់ដំបង | | | ៣៥ | ៩១០(៣.៨%) |
| ស្វាយរៀង | | | ៥៥ | ២១៦(២៥.៥%) |
| **ចំនួនសរុបសម្រាប់ពន្ធនាគារ១១ក្នុងឆ្នាំ២០១២** | | | **៧៩៧** | **៥,១៨២(១៥.៤%)** |

[៣៦] តួលេខក្នុងរង់ក្រចកបង្ហាញនូវភាគរយនៃពិរុទ្ធជនទាំងអស់ជាប់បណ្តឹងឧទ្ធរណ៍។

[៣៧] គ្មានទិន្នន័យទេក្នុងឆ្នាំ២០១០ សំរាប់ពន្ធនាគារខេត្តកំពង់ស្ពឺ កំពត បាត់ដំបង ស្វាយរៀង និងពន្ធនាគារខេត្តកំពង់ចាម។

តាមការប្រៀបធៀបពន្ធនាគារចំនួន ៧ ដែលបានរាយការណ៍ពីទិន្នន័យក្នុងឆ្នាំ ២០១០ និងឆ្នាំ២០១២ ស្ថានភាពស្ទើរតែគ្មានការប្រែប្រួល។ មានពិរុទ្ធជននៅតែជាប់បណ្តឹងឧទ្ធរណ៍ចំនួនប្រហែល ១៧% ដែលឃុំខ្លួននៅរាជធានីភ្នំពេញ ហើយគ្មានឱកាសបានទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ ចំនួនសរុបជនជាប់ឃុំដែលបង្ហាញពីពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ ១៥.៤% បង្ហាញពីការថយចុះតិចតួចចាប់ពីឆ្នាំ ២០១០។ ប៉ុន្តែវាពិបាកនឹងលើកទឹកចិត្ត ដោយសារតែជនជាប់ឃុំមានចំនួនសរុបជិត ៨០០ នាក់។

## ទិន្នន័យសម្រាប់បណ្តាពន្ធនាគារនៅជាយរាជធានីភ្នំពេញ

មិនមានសេចក្តីបញ្ជាក់ច្បាស់លាស់ទេ ថាតើពន្ធនាគារទាំងឡាយ នៅជាយរាជធានីភ្នំពេញ ត្រូវបានគេប្រើប្រាស់សម្រាប់ផ្ទុកជនជាប់ឃុំដែលជាប់បណ្តឹងឧទ្ធរណ៍ ឬក៏អត់ទេ។ អង្គការលីកាដូ បានលើកអនុសាសន៍ក្នុងរបាយការណ៍ឆ្នាំ២០១០ ថា ជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍នៅជាយរាជធានីភ្នំពេញ មិនគួរត្រូវផ្ទេរទៅកាន់ពន្ធនាគារនៅតាមបណ្តាខេត្តឡើយ លើកលែងតែបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ បានដំណើរការចប់សព្វគ្រប់តាមផ្លូវច្បាប់។ តាមដឹងមកថាព្រះរាជអាជ្ញា និងចៅក្រមបានធ្វើអនុសាសន៍បែបនេះទៅអគ្គនាយកដ្ឋានពន្ធនាគារ។ ប្រព័ន្ធគ្រប់គ្រងពន្ធនាគារមួយបែបនេះ នឹងធ្វើឲ្យការដឹកជញ្ជូនជនជាប់ឃុំមកកាន់តុលាការមានភាពងាយស្រួល និងចំណាយថវិកាតិចតួចជាង។



*អ្នកជាប់ឃុំតម្រង់ជួរក្នុងពន្ធនាគារខេត្តកោះកុង*

ពន្ធនាគារភាគច្រើនបំផុតនៅជាយរាជធានីភ្នំពេញ មិនបានចែករំលែកទិន្នន័យបណ្តឹងឧទ្ធរណ៍ជាមួយអង្គការលីកាដូឡើយនៅឆ្នាំ២០១២ ប៉ុន្តែអាចទទួលបានការពិពណ៌នាត្រួសៗពីស្ថានភាពនេះ ដោយធ្វើការប្រៀបធៀបទិន្នន័យបណ្តឹងឧទ្ធរណ៍ថ្មីៗបំផុតពីអគ្គនាយកដ្ឋានពន្ធនាគារដែលមានស្រាប់នៅខែវិច្ឆិកា ឆ្នាំ២០១១ ទៅនឹងទិន្នន័យ

ខែកុម្ភៈ ឆ្នាំ២០១២ របស់អង្គការលីកាដូ។ នៅខែវិច្ឆិកា អគ្គនាយកដ្ឋានពន្ធនាគារបាន រាយការណ៍អំពីចំនួនជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍សរុបទូទាំងប្រទេស ៩៩៣ នាក់។ នៅ ខែកុម្ភៈអង្គការលីកាដូ បានរកឃើញថា មានជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍ចំនួន ៧៩៧ នាក់កំពុងជាប់ឃុំនៅតាមបណ្ដាខេត្ត។ តាមសេចក្ដីរាយការណ៍ពីអគ្គនាយកដ្ឋាន ពន្ធនាគារនៅខែវិច្ឆិកា ឆ្នាំ២០១១ ពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍មានចំនួនសរុបប្រហែល ៨០% ក្នុងចំណោមដើមបណ្ដឹងឧទ្ធរណ៍ទាំងអស់ដែលជាជនជាប់ឃុំ។ ប្រសិនបើទិន្នន័យនោះត្រឹមត្រូវ នឹងទំនងថាបន្ទប់ឃុំខ្លួននៅតាមពន្ធនាគារជាយរាជធានីភ្នំពេញមិនត្រូវបានផ្ដល់អាទិភាពសម្រាប់ពិរុទ្ធជន ដែលកំពុងជាប់បណ្ដឹងឧទ្ធរណ៍ឡើយ។

បណ្ដាពន្ធនាគារជាក់លាក់នៅជាយរាជធានីភ្នំពេញ ដែលទិន្នន័យរបាយការណ៍ទទួលបានដោយអង្គការលីកាដូនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២ មានរាប់បញ្ចូលនូវព័ត៌មានដូចខាងក្រោម:

- ពន្ធនាគារប៉េហ្ស៊ី PJ (Police Judiciaire prison) ផ្ទុកជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍ចំនួន ៦០ នាក់ ក្នុងចំណោមពិរុទ្ធជនចំនួន ១៥៥ នាក់។ នៅក្នុងឆ្នាំ២០១០ បានរាយការណ៍មកថា ពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍មានចំនួនសូន្យ។[៣៨]
- នៅខែកក្កដា ឆ្នាំ២០១១ មណ្ឌលអប់រំកែប្រែទី១ បានរាយការណ៍ថា មានពិរុទ្ធជន ១៧ នាក់ជាប់បណ្ដឹងឧទ្ធរណ៍ក្នុងចំណោមជនជាប់ឃុំសរុប ២,០៦៨ នាក់។ តាមភស្តុតាងដែលគួរឲ្យចាប់អារម្មណ៍បង្ហាញថា ចំនួនពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍ពិតប្រាកដមានចំនួនខ្ពស់ប្រហែលរាប់រយនាក់។
- នៅខែមករា ឆ្នាំ២០១០ ពន្ធនាគារខេត្តកណ្ដាលនៅជាយរាជធានីភ្នំពេញរាយការណ៍មកថាពន្ធនាគារនេះ មានផ្ទុកពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍ចំនួន ៩ នាក់ក្នុងចំណោមជនជាប់ឃុំទាំងអស់ ៥៤៧ នាក់។ ពន្ធនាគារនេះមិនបានរាយការណ៍ទិន្នន័យទៅអង្គការលីកាដូទេនៅឆ្នាំ២០១២ នេះ។
- មណ្ឌលអប់រំកែប្រែទី២ មិនបានផ្ដល់ទិន្នន័យបណ្ដឹងឧទ្ធរណ៍ទៅអង្គការលីកាដូទេ។

---

[៣៨] ចំនួនតួលេខឆ្នាំ២០១០ ទំនងជាមិនត្រឹមត្រូវ ដោយសារតែពន្ធនាគារប៉េហ្ស៊ីមានកេរ្តិ៍ឈ្មោះ ជាពន្ធនាគារវីអាយភីរបស់ប្រទេសកម្ពុជា។ ជនជាប់ឃុំបានប្រាប់អង្គការលីកាដូ ថា ទណ្ឌិត និងពិរុទ្ធជនត្រូវបង់លុយកាក់យ៉ាងច្រើន ដើម្បីធានាសុវត្ថិភាពសម្រាប់បន្ទប់ឃុំខ្លួនអំណោយផលល្អរយៈពេលយូរ។ វាជាពន្ធនាគារតែមួយនៅកម្ពុជា ដែលផ្ទុកជនជាប់ឃុំមិនលើសចំណុះ។ សូមមើល "នៅតែលើសចំណុះ: របាយការណ៍លើកទី២ ស្ដីពីជនជាប់ឃុំតាមពន្ធនាគាររបស់ប្រទេសកម្ពុជាកាន់តែមានចំនួនកើនឡើង" របាយការណ៍អង្គការលីកាដូ បោះពុម្ពផ្សាយនៅខែកក្កដា ឆ្នាំ២០១១។

# ៤. អនុសាសន៍ទាំងឡាយ

នៅក្នុងឆ្នាំ២០១០ អង្គការលីកាដូ បានផ្ដល់អនុសាសន៍បឋមចំនួនពីរជូនដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានគោលដៅលើកយកបញ្ហាសវនាការកំបាំងមុខលើបណ្ដឹងឧទ្ធរណ៍មកដោះស្រាយ។ ខាងក្រោមនេះ យើងលើកអនុសាសន៍[៣៩]ទាំងពីរនេះមករំលឹកឡើងវិញ ព្រមទាំងពិនិត្យមើលភាពរីកចំរើន ដែលបានធ្វើឡើងលើចំណុចនីមួយៗ:

**ទី១ អង្គការលីកាដូ បានលើកអនុសាសន៍ថា អគ្គនាយកដ្ឋានពន្ធនាគារមិនគួរផ្ទេរជនជាប់ឃុំពីរាជធានីភ្នំពេញទៅកាន់បណ្ដាខេត្តឡើយ លើកលែងតែបណ្ដឹងឧទ្ធរណ៍របស់អ្នកទាំងនោះបានដំណើរការតាមផ្លូវច្បាប់ចប់សព្វគ្រប់។**

ជាសំណើរចំពោះដំណោះស្រាយរយៈពេលខ្លីនេះ អគ្គនាយកដ្ឋានពន្ធនាគារត្រូវពិនិត្យមើលស្ថានភាពផ្លូវច្បាប់របស់ជនជាប់ឃុំឲ្យបានដិតដល់មុនពេលផ្ទេរអ្នកទាំងនោះទៅកាន់ពន្ធនាគារនៅក្រៅរាជធានីភ្នំពេញ។ បើទុកជាអគ្គនាយកដ្ឋានពន្ធនាគារបានចាត់វិធានការក្នុងទិសដៅនេះ ពោលគឺបានផ្ដើមគំនិតធ្វើការសិក្សាវាយតម្លៃជនជាប់ឃុំជាមួយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាក៏មិនមានភាពច្បាស់លាស់ថា មានភាពជឿនលឿនគួរកត់សំគាល់ក្នុងវិស័យនេះដែរ ។ ដោយវិនិច្ឆ័យតាមទិន្នន័យដែលអគ្គនាយកដ្ឋានពន្ធនាគារបានផ្សព្វផ្សាយជាសាធារណៈ និង/ឬ ដែលអង្គការលីកាដូ ទទួលបានរបាយការណ៍នេះ មានជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍រហូតដល់ទៅ៨០% ដែលកំពុងឃុំខ្លួននៅក្រៅរាជធានីភ្នំពេញ។ ចាំបាច់ត្រូវការឲ្យមានប្រព័ន្ធឃ្លាំមើលស្ថានភាពបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ឃុំឲ្យបានប្រសើរជាងនេះ។

កិច្ចសហការ និងការប្រាស្រ័យទាក់ទងជាមួយក្រសួងយុត្តិធម៌ និងតុលាការហាក់ដូចជាមិនមានភាពជឿនលឿនទៅមុខក្នុងវិស័យនេះ។ មន្ត្រីពន្ធនាគារនៅតែបន្តរាយការណ៍ថា មិនមានព័ត៌មានច្បាស់លាស់ស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ឃុំនៅឡើយ។

---

[៣៩] សម្រាប់អត្ថបទទាំងស្រុងនៃអនុសាសន៍ដើម សូមមើល "ការជម្រះក្ដីកំបាំងមុខជនជាប់ចោទ: សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា: របាយការណ៍អង្គការលីកាដូ ខែមីនា ឆ្នាំ២០១០ ទំព័រ ៥-៧។

ទីបំផុតអង្គការលីកាដូ បានកត់សម្គាល់ក្នុងឆ្នាំ២០១០ ថាភាពចង្អៀតណែននៅតាមពន្ធនាគារក្នុងជាយរាជធានីភ្នំពេញនៅតែធ្វើឲ្យមានការលំបាកក្នុងការស្វែងរកទីធ្លាបន្ទប់ឃុំខ្លួនសម្រាប់ពិរុទ្ធជនជាដើមបណ្តឹងឧទ្ធរណ៍។ គិតមកដល់ត្រឹមខែធ្នូ ឆ្នាំ២០១១ មណ្ឌលអប់រំកែប្រែទី១ បានផ្ទុកជនជាប់ឃុំចំនួនរហូតដល់ទៅ១៧៣% នៃសមត្ថភាពផ្ទុករបស់ខ្លួន រីឯមណ្ឌលអប់រំកែប្រែទី២ និងពន្ធនាគារខេត្តកណ្តាលវិញបានផ្ទុកជនជាប់ឃុំដោយឡែកៗពីគ្នាចំនួនរហូតដល់ ១៨៥% និង ៣០៦%។ ចំនួនជនជាប់ឃុំនៅតាមពន្ធនាគារ ដែលអង្គការលីកាដូ បានឃ្លាំមើលមានការកើនឡើងប្រហែល ១២% នៅចន្លោះខែមករា ឆ្នាំ២០១០ និងខែមករា ឆ្នាំ២០១២ ថ្វីបើទីបំផុតចំនួនកើនជារួមនេះ បានធ្លាក់ចុះមកវិញនៅឆមាសទី២ ឆ្នាំ២០១១ ក៏ដោយ។

**ទី២ អង្គការលីកាដូ បានលើកអនុសាសន៍ថា អគ្គនាយកដ្ឋានពន្ធនាគារត្រូវពង្រីកបណ្តាញមធ្យោបាយដឹកជញ្ជូនជនជាប់ឃុំ និងប្រមូលផ្តុំការទទួលខុសត្រូវសម្រាប់ធ្វើការផ្ទេរបណ្តឹងឧទ្ធរណ៍។**

អង្គការលីកាដូ បានស្នើយោបល់ជាក់លាក់ថា អគ្គនាយកដ្ឋានពន្ធនាគារត្រូវបង្កើនបុគ្គលិកបន្ថែម និងផ្គត់ផ្គង់មូលនិធិសម្រាប់កម្មវិធីដឹកជញ្ជូនជនជាប់ឃុំតាមពន្ធនាគារដែលអាចចាត់ការក្នុងការផ្ទេរពិរុទ្ធជនពីខេត្តជាទៀងទាត់ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅភ្នំពេញ។ យើងបានកត់សម្គាល់ផងដែរចំពោះកង្វល់ខាងភស្តុភាងដែលត្រូវការ លើកមកដោះស្រាយ ឧៈការផ្តល់ទីធ្លាដាក់គ្រែសម្រាប់ពិរុទ្ធជនមកពីបណ្តាខេត្តដែលត្រូវឃុំខ្លួននៅរាជធានីភ្នំពេញនៅអំឡុងពេលដំណើរការឧទ្ធរណ៍ ព្រមទាំងផ្តល់មធ្យោបាយធ្វើដំណើរមក និងត្រឡប់ទៅកាន់តុលាការនៅពេលដែលអ្នកទាំងនោះបានមកដល់រាជធានីភ្នំពេញ។

ការបោះជំហានសមរម្យបំផុតហាក់បីដូចជា ត្រូវតែបានធ្វើឡើងឈានឆ្ពោះទៅរកការ
បំពេញអនុសាសន៍នេះ ដូចជាសំណើរបស់អគ្គនាយកដ្ឋានពន្ធនាគារសុំថវិកាសម្រាប់ទិញប្រេងសាំង និងសំណើសុំថវិកាទិញរថយន្តបន្ថែមនៅឆ្នាំ២០១១ សម្រាប់ដឹកជញ្ជូនជនជាប់ឃុំ។ ថ្វីបើអង្គការលីកាដូទទួលស្គាល់ថា ការបង្កើតមធ្យោបាយរួមសម្រាប់ដឹកជញ្ជូនជនជាប់ឃុំ គឺជាគោលដៅមួយត្រូវប្រើពេលយូរ ដែលតម្រូវឲ្យមានការប្តេជ្ញាចិត្តខ្លាំងក្នុងការផ្តល់ថវិកា និងការបណ្តុះបណ្តាលក៏ដោយក៏មានការខកចិត្តដោយសារសង្កេតឃើញថា

មានភាពរីកចំរើនទៅមុខតិចតួចត្រូវបានគេធ្វើឡើងនៅអំឡុងពេល ២ ឆ្នាំកន្លងទៅនេះ។ ជាថ្មីម្តងទៀត យើងខ្ញុំសូមជម្រុញអាជ្ញាធរឲ្យកំណត់មូលនិធិជាអាទិភាពសម្រាប់ទិញប្រេងសាំង និងទិញរថយន្តដឹកជញ្ជូនជនជាប់ឃុំនៅតាមពន្ធនាគារ។

ដោយសារមិនមានភាពជឿនលឿនក្នុងវិស័យនេះ អង្គការលីកាដូ ស្នើសុំយោបល់ថា អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងយុត្តិធម៌ និងតុលាការ ត្រូវស្វែងរកដំណោះស្រាយផ្សេងៗ ជាបណ្តោះអាសន្នតាមដែលអាចធ្វើបាន។ សេចក្តីស្នើយោបល់ទាំងនេះមិនអាចចាត់ទុកជាការជំនួសឲ្យការបង្កើតប្រព័ន្ធដឹកជញ្ជូនជនជាប់ឃុំសមស្របមួយបានទេ។ ផ្ទុយទៅវិញសេចក្តីស្នើយោបល់ទាំងនេះ មានន័យថាជាសេចក្តីស្នើយោបល់បំពេញបន្ថែមដែលនឹងផ្តល់កិច្ចការពារទល់នឹងការដកហូតជាប្រព័ន្ធ និងកំពុងបន្តមាននូវសិទ្ធិរបស់ជនជាប់ឃុំក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ សេចក្តីស្នើយោបល់ទាំងនេះរួមមាន:

- *"រៀបចំជាក្រុមៗ" នូវបណ្តឹងឧទ្ធរណ៍របស់ជនជាប់ឃុំគ្នាច្រើន ដែលឃុំខ្លួននៅក្នុងពន្ធនាគារមួយ*តាមបណ្តាខេត្ត។ បើសាលាឧទ្ធរណ៍អាចរៀបចំឡើងវិញនូវបញ្ជីសំណុំរឿងរបស់ខ្លួនសម្រាប់សវនាការ ពិរុទ្ធជនចំនួនច្រើននាក់រួមគ្នាអាចត្រូវដឹកមកកាន់រាជធានីភ្នំពេញដើម្បីចូលរួមសវនាការ[៤០] លើបណ្តឹងឧទ្ធរណ៍របស់ខ្លួនធ្វើដូច្នេះ នឹងកាត់បន្ថយតម្លៃសម្រាប់មធ្យោបាយធ្វើដំណើរ។ លទ្ធភាពនៃសេចក្តីស្នើនេះ បានកើនឡើងនៅដើមឆ្នាំនេះ ដែលបន្ទប់សវនាការថ្មីចំនួន ២ បន្ទប់នៅសាលាឧទ្ធរណ៍បានចាប់បើកឲ្យដំណើរការ។
- *បង្កើតសាលាឧទ្ធរណ៍បន្ថែមនៅកម្រិតតំបន់ ដែលសាលាឧទ្ធរណ៍និមួយៗ មានសមត្ថកិច្ចទៅលើស្រុកគោលដៅនៃខេត្តមួយចំនួន។* ប្រទេសកម្ពុជាមានសាលាឧទ្ធរណ៍តែមួយគត់ ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញជាហេតុការណ៍មួយធ្វើឲ្យចំណាត់ការនីតិវិធីច្បាប់មានភាពស្មុកស្មាញសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ មិនមែនសម្រាប់តែជនជាប់ឃុំប៉ុណ្ណោះទេ។ រដ្ឋាភិបាលលោកគួរតែពិនិត្យពិចារណាក្នុងការបែងចែក

[៤០] តាមពិតនេះមិនមែនមានន័យថា ត្រូវបើកសវនាការលើបណ្តឹងឧទ្ធរណ៍សម្រាប់ជនជាប់ចោទច្រើននាក់នៅពេលតែមួយរួមគ្នានោះទេ មានន័យថាត្រូវបើកសវនាការលើបណ្តឹងឧទ្ធរណ៍ដោយឡែកៗពីគ្នាសម្រាប់ជនជាប់ចោទម្នាក់ៗ។

ប្រទេសឲ្យទៅជាស្រុកមួយចំនួនក្តោបបណ្តឹងឧទ្ធរណ៍នៅកំរិតតំបន់មួយៗ ឲ្យមានសាលាឧទ្ធរណ៍មួយបំរើសេវាឲ្យតំបន់នោះ។ ស្រុកនីមួយៗអាចមានសមត្ថកិច្ចទៅលើខេត្តមួយចំនួន ដែលស្ថិតក្នុងតំបន់មួយតាមលក្ខណៈភូមិសាស្ត្រជាក់លាក់។ អត្ថិភាពនៃសាលាឧទ្ធរណ៍នៅថ្នាក់តំបន់អាចកាត់បន្ថយតំលៃ ក្នុងការដឹកជញ្ជូនពិរុទ្ធជនទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍។ ជម្រើសផ្សេងពីនេះទៅទៀតស្រុកមួយចំនួនអាចត្រូវកំណត់គោលដៅជា "តុលាការមណ្ឌល" ដោយមានសាលាឧទ្ធរណ៍ច្រើនកន្លែង ដែលចៅក្រមអាចធ្វើដំណើរទៅបានតាមសេចក្តីត្រូវការជាមូលដ្ឋាន។ ជម្រើសនេះនឹងកាត់បន្ថយតម្លៃនៃការដឹកជញ្ជូនកាន់តែតិចទៅៗសម្រាប់ជនជាប់ឃុំ។

- *សាលាឧទ្ធរណ៍ចល័ត។* គំនិតនេះ គឺស្រដៀងគ្នាទៅនឹងគំនិត ដែលបានលើកឡើងខាងលើទាក់ទងនឹងតុលាការមណ្ឌល ប៉ុន្តែអាចពាក់ព័ន្ធទៅនឹងតុលាការមួយ ដែលត្រូវធ្វើដំណើរយ៉ាងច្រើន ហើយអាចមានទីតាំងនៅក្នុងរាជធានីភ្នំពេញជាជាងនៅក្នុងមណ្ឌលថ្នាក់តំបន់នានា។ ជំនួសការធ្វើដំណើរមកកាន់តុលាការរបស់ជនជាប់ឃុំ ដោយចៅក្រមត្រូវធ្វើដំណើរទៅកាន់ជនជាប់ឃុំទៅវិញ។ តុលាការចល័តទាំងឡាយត្រូវបានគេប្រើប្រាស់ប្រកបដោយជោគជ័យនៅក្នុងប្រទេសផ្សេងៗ[៤១] ហើយក្នុងករណីខ្លះរថយន្តដឹកជញ្ជូនទាំងឡាយ - បំប្លែងទៅជារថយន្តធំៗ - ត្រូវបំរើជាបន្ទប់សវនាការពិតៗ។ ជម្រើសក្រៅពីនេះ សវនាការទាំងឡាយអាចត្រូវធ្វើនៅក្នុងពន្ធនាគារ ឬ ត្រូវធ្វើនៅក្នុងតុលាការរាជធានី/តុលាការខេត្ត។
- *សវនាការពីចម្ងាយភ្ជាប់ដោយប្រព័ន្ធវីឌីអូ។* បច្ចេកទេសនេះ ត្រូវបានគេប្រើក្នុងបរិបទច្បាប់ផ្សេងៗនៅទីកន្លែងដ៏ទៃៗទៀតជាអាទិភាពសម្រាប់ឲ្យសាក្សីផ្តល់សក្ខីកម្ម។ ប៉ុន្តែមានការកម្រិតព្រំដែនជាសារៈសំខាន់ក្នុងការប្រើបច្ចេកទេសបែបនេះ ចំពោះសាលាឧទ្ធរណ៍នៅប្រទេសកម្ពុជា។ ទី១ ប្រព័ន្ធវីឌីអូ ដែលកំពុងមានចលនារូបភាព និងសំឡេង គឺស្ថិតនៅទីឆ្ងាយជំនួសវត្តមានជាក់ស្តែងពិតៗ របស់ចុងចោទនៅក្នុងបន្ទប់

---

[៤១] ប្រទេសដែលបានប្រើប្រាស់តុលាការចល័ត រួមមានហ្វីលីពីន Guatemala ប្រេហ្ស៊ីល Bangladesh ឥណ្ឌា លាវ នីហ្សេរីយ៉ា និងសហរដ្ឋអាមេរិក។ សូមមើល Merzenaida Donovan, " ចូលកាន់តែជិតជនក្រីក្រ: នាំយកយុត្តិធម៌ទៅកៀកជនក្រីក្រ", កម្មវិធីសកម្មភាពសំរាប់កំណែទំរង់តុលាការ (អាចរកបានតាមគេហ ទំព័ http://apjr.judiciary.gov.ph/news_2007/archive_featurearticle003.html)។

សវនាការ។ ឧ: ការប្រើបណ្តាញបញ្ជូនរូបភាព និងសំឡេងដោយភ្ជាប់ប្រព័ន្ធវីឌីអូអាច មានអនុភាពមួយឆ្ងាយដាច់ពីគ្នារវាងចុងចោទ និងមនុស្សទាំងឡាយ ដែលមាន វត្តមាន នៅក្នុងបន្ទប់សវនាការរាប់ទាំងមេធាវីការពារក្តីផង។ ចុងចោទនឹងទទួលបានការយល់ដឹងមានកម្រិតផងដែរ - ហើយតាមន័យត្រង់មើលឃើញរូបភាពមានកំរិត ដោយផ្តែក លើអ្វី ដែលប្រព័ន្ធវីឌីអូបានបង្ហាញ - ពីចំណាត់ការនីតិវិធីក្នុងបន្ទប់សវនាការ។ ទី២ មានបញ្ហាបច្ចេកទេស: ពន្ធនាគារភាគច្រើនមិនត្រឹម តែខ្វះខាតគ្រឿងបរិក្ខារ កុំព្យូទ័រ និងការភ្ជាប់បណ្តាញអ៊ិនធ័រណិតឲ្យបានគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនមាន បណ្តាញភ្លើងអគ្គិសនី ដែលគួរឲ្យទុកចិត្តបានទៀតផង។ បញ្ហាខ្លះក្នុងចំណោមបញ្ហា ទាំងនេះ គួរតែត្រូវពុះពារជំនះឲ្យបានតាមរយៈតំឡើងគ្រឿងបរិក្ខារ សវនាការ ដោយ ភ្ជាប់ប្រព័ន្ធវីឌីអូនៅតាមតុលាការរាជធានី និងតុលាការនៅមូលដ្ឋាន។ ប៉ុន្តែតំលៃនៅតែ អាចថ្លៃហួសហេតុពេក។ អង្គការលីកាដូ ជឿជាក់ថា ជម្រើសនេះ មិនមែនជាវិធានការ សមស្របក្នុងការដោះស្រាយវិបត្តិដឹកជញ្ជូនជនជាប់ឃុំនៅកម្ពុជាឡើយ ប៉ុន្តែជម្រើស នេះអាចប្រើក្នុងកាលៈទេសៈដែលមានកំរិតបំផុត ដូចជាប្រើសម្រាប់ឲ្យសាក្សីផ្តល់សក្ខីកម្មជាដើម។

□□□